# របាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១៥ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **<u>ស្ថានភាពមន្ត្រីរាជការ</u>**÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣១ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **<u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>**÷

- ចូលរួមវេទិកាសាធារណៈចំនួន ០៦ដង
- ចូលរួមពិធីសំណេះសំណាល និងស្វាគមន៍គណៈប្រតិភូក្រុង Rizhao ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ នៅសាលប្រជុំខេត្តក្រចេះ
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១៧ អណត្តិទី២ ឆ្នាំទី២ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០១៥ សាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំបណ្តាញយេនឌ័រថ្នាក់ខេត្ត ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីថ្នាក់ខេត្ត
- ចូលរួមវេទិកាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីសិទ្ធិទទួលព័ត៌មានវិស័យអប់រំ នៅមូលដ្ឋានសហគមន៍ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥
- ចូលរួមប្រជុំពង្រឹងគណៈកម្មាធិការប្រយុទ្ធជំងឺគ្រុនចាញ់ ប្រចាំត្រីមាសទី៤ ឆ្នាំ ២០១៥ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ សាលប្រជុំមន្ទីរសុខាភិបាលខេត្តក្រចេះ
- ចូលរួមប្រជុំបូកសរុបវេទិកាសាធារណៈ ថ្ងៃទី ៣០ ខែតុលា ២០១៥ នៅសាលមហោស្រព
- ចូលរួមប្រជុំសាមញ្ញគណៈគម្មាធិកាពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ សាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមពិធីប្រកាសតែងតាំងប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមទិវាបុណ្យឯករាជ្យជាតិ ០៩ វិច្ឆិកា ២០១៥ នៅថ្ងៃទី ០៩ វិច្ឆិកា ២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគោលនយោបាយ និងឯកសារគតិយុត្តិ ពាក់ព័ន្ធការងាររៀបចំដែនដីដល់ប្រជាពលរដ្ឋថ្នាក់ក្រោមជាតិ ថ្ងៃទី១៦ វិច្ឆិកា ២០១៥ នៅសាលមហោស្រព
- ចូលរួមប្រជុំណែនាំ ស្តីពី ការរៀបចំបច្ចុប្បន្នភាពគម្រោងវិនិយោគ របស់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តក្រចេះ ១៣ វិច្ឆិកា ២០១៥ នៅមន្ទីរផែនការខេត្តក្រចេះ

- ចូលរួមប្រជុំបូកសរុបការងារលើគ្រប់វិស័យ ប្រចាំខែតុលា ថ្ងៃទី១៧ វិច្ឆិកា ២០១៥ នៅសាលប្រជុំសាលាខេត្ត
- សំណើ និងដំណោះស្រាយនៃវេទិការសាធារណៈប្រចាំស្រុកឆ្លូង នៅសាលាខេត្តក្រចេះ ថ្ងៃទី១៩ វិច្ឆិកា ២០១៥
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងទិវាលាងសម្អាតដៃ ថ្ងៃទី២៨ វិច្ឆិកា ២០១៥ នៅវត្តបុសលាវ ។

3. **<u>សកម្មភាពតាមការិយាល័យ</u>**÷

3.1. **<u>ការិយាល័យរដ្ឋបាល និងបុគ្គលិក</u>**÷

ក. <u>ផ្នែកការងារលិខិតចូល</u> ÷ សរុបចំនួន ៦៩ លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០២ លេខ
- លិខិតរបស់ក្រសួងសាមី ចំនួន ១៣ លេខ
- លិខិតក្រសួងនានា ចំនួន ០៤ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៥០ លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ៤៤ លេខ ក្នុងនោះមានៈ

- លិខិតទៅនាយកដ្ឋាន និងក្រសួង ចំនួន ១៥ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ២៩ លេខ

គ. <u>លិខិតឧទ្ទេសនាម</u>÷ សរុប ចំនួន ០២ លេខ

ឃ. <u>ផ្នែកការងារលិខិតបញ្ជាបេសកកម្ម</u>÷ សរុប ចំនួន ៣២ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកម្មលោកប្រធានមន្ទីរ ពី **ឯកឧត្តមអភិបាលខេត្ត** ចំនួន ០៥ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រី ចំនួន ២៧ លេខ

ង. <u>ផ្នែកបញ្ជីវត្តមាន</u>÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. **<u>ការិយាល័យផ្លូវជនបទ</u>**÷

**សកម្មភាពការងារ** ÷

- ចុះពិនិត្យ និងវាយតម្លៃសិក្សាផ្លូវបន្ទាន់ចំនួន ០២ ខ្សែ ប្រវែង ៣,២០០ម៉ែត្រ ស្ថិតនៅក្នុងឃុំថ្មគ្រែ ឃុំសំបក ស្រុកចិត្របុរី ជាមួយក្រុមការងារអន្តរក្រសួង (ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)
- ចុះពិនិត្យការងារជួសជុលផ្លូវថែទាំជាលក្ខណៈប្រចាំ សម្រាប់សុពលភាពផ្លូវ សោប-ស្រែវៀត ប្រវែង ១១,៧០០ ម៉ែត្រ ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំសោប ស្រុកព្រែកប្រសព្វ និងផ្លូវវង្សនៈ ទៅ យាវ ប្រវែង ៩,៦០០ ម៉ែត្រ ស្ថិតនៅឃុំវង្សនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរ បាន ០២លើក

- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈប្រចាំផ្លូវស្រែទ្រៀក-វាលកន្សែង ប្រវែង ៦,៣០០ ម៉ែត្រ ស្ថិតនៅឃុំជីរោទ៍ និងផ្លូវរលៀក-ប្រម៉ា ប្រវែង ១០,៨០០ ម៉ែត្រ ស្ថិតនៅឃុំ កំពង់ជីវី ស្រុកត្បូង បានចំនួន ០៣លើក
- បញ្ជាក់បច្ចេកទេសគម្រោងមូលនិធិឃុំ -សង្កាត់ ស្រុក ឆ្នាំ២០១៥ របស់សាលាខេត្ត ទីចាត់ការផែនការ និងវិនិយោគ បានចំនួន ០៨ គម្រោង ។

**លទ្ធផលការងារ ÷**

- ការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប សម្រាប់សុពលភាពផ្លូវ សោប-ស្រែវៀត ប្រវែង ១១,៧០០ ម៉ែត្រ ស្ថិតនៅឃុំព្រែកប្រសព្វ ឃុំសោប ស្រុកព្រែកប្រសព្វ និងផ្លូវខ្សាច់ ទៅយាវ ប្រវែង ៩,៦០០ ម៉ែត្រ ស្ថិតនៅឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម លទ្ធផលសម្រេចបាន ១០០%
- ការងារជួសជុលថែទាំជាលក្ខណៈប្រចាំផ្លូវ ស្រែទ្រៀក-វាលកន្សែង ប្រវែង ៦,៣០០ ម៉ែត្រ ស្ថិតនៅឃុំជីរោទ៍ ស្រុកត្បូង និងផ្លូវ រលៀក-ប្រម៉ា ប្រវែង ១០,៨០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ជីវី ស្រុកត្បូង លទ្ធផលសម្រេចបាន ១០០%
- ការងារជួសជុលបន្ទាន់ផ្លូវ ចំនួន ០២ ខ្សែប្រវែង ៣,៣០០ ម៉ែត្រ ស្ថិតនៅក្នុងឃុំថ្មគ្រែ ឃុំសំបុក ស្រុកចិត្របុរីលទ្ធផលសម្រេចបាន ៧០% ។

3.3. **<u>ការិយាល័យផ្គត់ផ្គង់ទឹកជនបទ</u>** ÷

- ជួសជុលអណ្តូងស្នប់ ដីសម្បទានកំពី ឃុំសំបុក ០៣ អណ្តូង និងស្រុកព្រែកប្រសព្វ ឃុំជ្រោយបន្ទាយ ០១ អណ្តូង
- សាងសង់អណ្តូងស្នប់ថ្មីបានចំនួន ០៥ អណ្តូង
  - ស្រុកចិត្របុរី ០២ អណ្តូង
  - ស្រុកសំបូរ ០៣ អណ្តូង ។

3.4. **<u>ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ</u>**÷ (គ្មានសកម្មភាព)

3.5. **<u>ការិយាល័យអភិវឌ្ឍន៍សហគមន៍</u>**÷

- ចុះបណ្តុះបណ្តាល គ.អ.ភ ស្តីពីការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ ចំនួន ១២ វគ្គ នៅភូមិចំនួន៨៤ភូមិ ស្មើនឹង២៣ឃុំ/សង្កាត់ ក្នុងស្រុកចំនួន៤ និងក្រុង ១ ដែលមានអ្នកចូលរួមសរុបចំនួន ៤២០ នាក់ ក្នុងនោះស្ត្រីមាន១០៨នាក់
- ចុះបណ្តុះបណ្តាល គ.អ.ភ និងកសិករ ស្តីពី សញ្ញាណសន្តិសុខស្បៀង សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត នៅភូមិសំបូរសែនជ័យ និងភូមិវត្ត ក្នុងឃុំស្វាយជ្រះ ស្រុកស្នួល ដែលមានអ្នកចូលរួមសរុប ៤០នាក់ ក្នុងនោះស្ត្រីមានចំនួន ១២នាក់
- សហការជាមួយអង្គការឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ ដោយចុះបណ្តុះបណ្តាល គ.អ.ភ ស្តីពី ការប្រែប្រួលអាកាសធាតុ ការបន្សាំ និងការកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយ

នៅស្រុកឆ្លង បាន ៤ វគ្គ ស្មើនឹង ១៦ ភូមិ ស្មើនឹង ៤ ឃុំ និងអ្នកចូលរួមសរុប ១២០ នាក់ ក្នុងនោះស្ត្រីមានចំនួន ៤០ នាក់ ។

3.6. **<u>ការិយាល័យជនជាតិដើមភាគតិច</u>**÷ (គ្មានសកម្មភាព)

3.7. **<u>ការិយាល័យថែទាំសុខភាពជនបទ</u>**÷

- បំផុសអោយប្រជាពលរដ្ឋចូលរួមស្ម័គ្រចិត្តសាងសង់បង្គន់ខ្លួនឯង បានចំនួន ១៣៤ បង្គន់ នៅស្រុកព្រែកប្រសព្វ ៤៩ បង្គន់ ស្រុកឆ្លង ០៨ បង្គន់ និងស្រុកស្នួល ៧៧ បង្គន់ ។

3.8. **<u>ការងារបណ្តុះបណ្តាលមន្ត្រីរាជការ</u>**÷

- លោក ផន សារី អនុប្រធានមន្ទីរ លោក ផេង ស៊ីណិត លោក ម៉ៅ ឌឹម លោក ច័ន្ទ ប៊ុនរិទ្ធ មន្ត្រីការិយាល័យរដ្ឋបាល និងបុគ្គលិក បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងការងាររដ្ឋបាល និងបុគ្គលិក កាលពីថ្ងៃទី ០៥-០៦ ខែវិច្ឆិកា ឆ្នាំ ២០១៥ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ក្រោមការឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោក លឹម ជាវហាវ ប្រធានមន្ទីរ លោក ហៃ មិត ប្រធានការិយាល័យសុខភាពជនបទ លោក ជុន ដន ប្រធានការិយាល័យផ្គត់ផ្គង់ទឹកជនបទ លោក សោម ជួន អនុប្រធានការិយាល័យបណ្តុះបណ្តាល បានចូលរួមសិក្ខាសាលាអំពី លទ្ធផលសិក្សា ស្តីពី តម្រូវការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត កាលពីថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៥ ក្រោមការរៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោក ផន សារី បានចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគោលនយោបាយ និងឯកសារគតិយុត្តិ ពាក់ព័ន្ធការរៀបចំដែនដី ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៥ ក្រោមការរៀបចំដោយសាលាខេត្ត នៅសាលមហោស្រពខេត្ត ។
- លោក ផន សារី លោក តូច សួង លោក អ៊ុត អ៊ុល លោក ឈាងស៊ីថា លោក ឌិក រ៉េត លោក សារ សួពៀត លោក អ៊ុត អ៊ុល លោក ឌិក រ៉េត លោក សួង ម៉ាដែន បានចូលរួមក្នុងដំណើរការសិក្ខាសាលាសមាហរណកម្ម ផែនការវិនិយោគឃុំ សង្កាត់ ឆ្នាំ២០១៦ កាលពីថ្ងៃទី ១៦-២០ ខែវិច្ឆិកា ឆ្នាំ ២០១៥ ។

4. **<u>ទិសដៅបន្ត</u>**÷

- បន្តចុះសិក្សាជួសជុលផ្លូវបន្ទាន់ចំនួន ០២ ខ្សែ ប្រវែង ៣,៣០០ ម៉ែត្រស្ថិតនៅក្នុងឃុំថ្មគ្រែ ឃុំសំបុក ស្រុកចិត្របុរី
- បន្តជួយផ្តល់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស បទពិសោធន៍ក្នុងការជួសជុលអណ្តូងស្នប់ខូច ដល់ក្រុមប្រើប្រាស់ទឹក ស្រុកចិត្របុរី
- ចុះទៅបណ្តុះបណ្តាលគ.អ.ភស្តីពីការប្រែប្រួលអាកាសធាតុ ការបន្សាំ និងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ នៅស្រុកឆ្លង ចំនួន ៦ វគ្គទៀត

- បន្តការបំផុសអោយប្រជាពលរដ្ឋ ចូលរួមសាងសង់បង្គន់ដោយខ្លួនឯង ក្នុងស្រុកឆ្លូង ស្រុកចិត្របុរី ស្រុកព្រែកប្រសព្វ ស្រុកសំបូរ និងស្រុកស្នួល
- បន្តផ្តល់សម្ភារសាងសង់បង្គន់នៅ ឃុំវឌ្ឍនៈ ស្រុកព្រែកប្រសព្វ ។

**ប្រធានមន្ទីរ**